Civil society Links and Empowerment for Socially Inclusive Development in Ratanakiri



# គោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ខ្សែសង្វាក់តម្លៃ ស្វាយចន្ទី ក្នុងខេត្តរតនគិរី, ប្រទេសកម្ពុជា

***ILS LEDA***

ការសិក្សានេះត្រូវបានចងក្រងដោយអ្នកជំនាញរបស់ ILSLEDA ក្នុងក្របខ័ណ្ឌនៃគម្រោង "CLESIDRA: ការចងបណ្តាញ និងការពង្រឹងសង្គមស៊ីវិលសម្រាប់ការអភិវឌ្ឍន៍សង្គមបែបបរិយាបន្នក្នុងខេត្តរតនគិរី" ដែលសហការផ្តល់មូលនិធិដោយសហភាពអឺរ៉ុប។

*ខែវិច្ឆិកា ឆ្នាំ២០២៤*

FELCOSUMBRIA Associazione di Comuni per lo Sviluppo Sostenibile

ILS LEDA

Building Community Voices

UPWD

## ជំពូកទី ៥. គោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយការប្រកួតប្រជែង និងបរិយាប័ន្ន (ការរួមបញ្ចូល)

### ៥.១. វិធីសាស្ត្រក្នុងការបរិយាយលម្អិតនៃគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃស្វាយចន្ទី

វិធីសាស្ត្រ **រេស្កូ**(RESCO) សម្រាប់ការបកស្រាយលម្អិតនៃគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃសាច់គោ និងគោទឹកដោះគោ ប្រើប្រាស់ធាតុចូលនៃដំណើរការវាយតម្លៃ **រេស្កូ**(RESCO) (ការសម្ភាសន៍), ប្រើប្រាស់ទិន្នន័យបានពីការវិភាគលទ្ធផលនៃការស្រាវជ្រាវ និងពីការពិគ្រោះយោបល់ជាមួយអ្នកជំនាញ និងចាត់ថ្នាក់ការរកឃើញនៅទាំងអស់នេះក្នុងការអន្តរាគមន៍។

ធាតុចូលសំដៅទៅលើសូចនាករផលប៉ះពាល់នៃអថេរនីមួយៗដែលឆ្លើយតបនឹងកត្តានីមួយៗ ប្រសិនបើវាវិជ្ជមាន (ចំណុចខ្លាំង) ឬអវិជ្ជមាន (ចំណុចខ្សោយ) ដូចដែលបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម។




សកម្មភាពយុទ្ធសាស្ត្រសម្រាប់ឆ្លើយតបគួរត្រូវបានធ្វើឡើងដើម្បី៖

a. រក្សាចំណុចខ្លាំងក្នុងរយៈពេលយូរ
b. ដកចំណុចខ្សោយចេញ ព្រោះវាតំណាងឲ្យឧបសគ្គដល់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ។

ទីបំផុតវិធីសាស្ត្រ **រេស្កូ**(RESCO) ប្រើក្បួនដោះស្រាយសាមញ្ញមួយសម្រាប់ការទាញយកសកម្មភាពយុទ្ធសាស្ត្រសម្រាប់ "អថេរ" នីមួយៗដែលឆ្លើយតបទៅនឹង "កត្តា" ផ្សេងៗ។

រូបមន្តមានដូចខាងក្រោម៖

$Sa= f( V_{i,j}, Fa_n)$

*$Sa$= សកម្មភាពយុទ្ធសាស្ត្រ*

*$V_{i,j}$= អថេរ "i" នៃសមាសភាគ "j"*

*$Fa_n$= កត្តា "n"*

## ៥.២. ពីសក្តានុពល និងតម្រូវការ ទៅជាសកម្មភាព

សក្តានុពល និងតម្រូវការសំខាន់ៗដៅទៅលើកត្តានីមួយៗ និងអថេរនៃខ្សែសង្វាក់តម្លៃស្វាយចន្ទី ត្រូវបានបង្ហាញនៅក្នុងជំពូកទី 4 ។

ដំណើរការពីការអនុវត្តសកម្មភាពយុទ្ធសាស្ត្រ ទៅជាតម្រូវការដែលបានរៀបរាប់ខាងលើត្រូវបានគេមើលឃើញទុកជាមុនៈ

1. កំណត់សកម្មភាពបុគ្គលសម្រាប់អថេរនីមួយៗ
2. ចាត់ថ្នាក់ ឬបែងចែកសកម្មភាពបំពេញបន្ថែមជាក្រុម ឬតាមក្រុម
3. លុបបំបាត់ការចម្លង (អ្វីដែលដូចគ្នា ឬចម្លងចេញពីគ្នា)
4. រួមបញ្ចូលសកម្មភាពនីមួយៗក្នុងការឆ្លើយតបនឹង "ការអនុវត្តយុទ្ធសាស្ត្រ"

អាស្រ័យហេតុនេះ ការវាយតម្លៃដោយប្រើវិធីសាស្ត្រ **រេស្កូ**(RESCO) ក៏បានផ្តល់នូវសកម្មភាពយុទ្ធសាស្ត្រយ៉ាងតិចចំនួនបីផងដែរមានដូចជាៈ

a. អភិបាលកិច្ច
b. ការកសាងសមត្ថភាព
c. ប្រព័ន្ធសេវាកម្ម

ដោយពិចារណាលើអាទិភាពដែលកើតចេញពីការវិភាគស្ថានភាព និងសក្តានុពលនៃខ្សែសង្វាក់តម្លៃស្វាយចន្ទី និងគោលដៅរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) សកម្មភាពយុទ្ធសាស្ត្រទាំងនេះត្រូវបានចាត់ថ្នាក់ជាក្រុម(តាមក្រុម) ទៅតាមអាទិភាពទាំងបីកម្រិតរួមមានៈ

- **អាទិភាពលេខ ១**ៈ សកម្មភាពដែលឆ្លើយតបទៅនឹងគោលបំណង និងសំណើនៃផែនការការងាររបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) (សូមមើលប្រអប់ទី ១) ហើយក្នុងពេលជាមួយគ្នានេះ វាក៏ឆ្លើយតបទៅនឹង "អាទិភាពខ្ពស់ (HP)" ដែលបង្ហាញដោយក្រុម **រេស្កូ**(RESCO)
- **អាទិភាពលេខ ២**ៈ សកម្មភាពដែលឆ្លើយតបទៅនឹង "អាទិភាពខ្ពស់ (HP)" ដែលបង្ហាញដោយក្រុម **រេស្កូ**(RESCO) ប៉ុន្តែមិនត្រូវបានមើលឃើញដោយគម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នោះទេ ហើយវានឹងតម្រង់ទិសផែនការបីឆ្នាំរបស់ [វេទិកា**ផ្លាសិដ**(PLASED), គណៈកម្មាធិការខ្សែសង្វាក់តម្លៃស្វាយចន្ទី និង ប្រព័ន្ធសេវាកម្មទូលំទូលាយ **កុស្ស**(COSS)]
- **អាទិភាពលេខ ៣**ៈ សកម្មភាពឆ្លើយតបទៅនឹង "អាទិភាពមធ្យម (MP)" ដែលបង្ហាញដោយក្រុម **រេស្កូ**(RESCO)

**ប្រអប់ទី ១ៈ ផែនការការងារគម្រោង ខ្លេស៊ីដ្រា**(CLESIDRA)

| |
|---|
| WP1 - **ការធ្វើឲ្យប្រសើឡើងនូវជំនាញរបស់សង្គមស៊ីវិល អ្នកផលិត និងអាជ្ញាធរ ទៅលើកិច្ចសន្ទនាពហុភាគី, ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម** |
| A1.1 ការកសាងសមត្ថភាពសម្រាប់សង្គមស៊ីវិលស្តីពីការចូលរួមយ៉ាងសកម្មក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងកិច្ចសន្ទនាពហុភាគី។ |

DRAFT

A1.2 វគ្គបណ្តុះបណ្តាលស្តីពី ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និង ការប្រកួតប្រជែងនិងនិរន្តរភាពនៃខ្សែសង្វាក់តម្លៃ។
A1.3 វគ្គបណ្តុះបណ្តាល និងការគាំទ្រដើម្បីបង្កើនសមត្ថភាពរបស់សង្គមស៊ីវិល (អភិបាលកិច្ចផ្ទៃក្នុង ផលប៉ះពាល់ ការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ ការស្វែងរកកាគាំទ្រ ការបង្កើតគម្រោង និងការគ្រប់គ្រងគម្រោង)
A.1.4 វគ្គបណ្តុះបណ្តាល និងការផ្តល់ជំនួយបច្ចេកទេសដល់សង្គមស៊ីវិលលើបច្ចេកទេស/វិធីសាស្ត្រតម្លៃប្រកបដោយនិរន្តរភាព ការអភិរក្សធនធានធម្មជាតិ និងសន្តិសុខរបស់កសិករខ្នាតតូច [រួមទាំងសិទ្ធិកាន់កាប់(ដីធ្លី)]

WP2 - **ការបង្កើតវេទិកា ផ្លាសិដ**(PLASED) ***(វេទិកាសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព)***
A2.1៖ ការផ្តល់ជំនួយបច្ចេកទេសក្នុងការរចនា និងការចាប់ផ្តើមវេទិកា **ផ្លាសិដ**(PLASED)
A2.2: ការចាប់ផ្តើមនៃវេទិកា **ផ្លាសិដ**(PLASED) និងការអនុវត្តសកម្មភាពយុទ្ធសាស្ត្រ
A2.3៖ ការបង្កើត ការបោះពុម្ពផ្សាយ និងចរាចរកូនសៀវភៅស្តីពី បទពិសោធន៍របស់វេទិកា **ផ្លាសិដ**(PLASED)

WP3 - **ការបរិយាយលម្អិតដោយមានការចូលរួមនៃយុទ្ធសាស្ត្រ**(STRAT) **សម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃប្រកបដោយការប្រកួតប្រជែង បរិយាប័ន្ន និរន្តរភាព និងភាពធន់។**

WP4 - **ការបង្កើត ប្រព័ន្ធសេវាកម្មទូលំទូលាយ កុស្ស**(COSS)
A4.1 ការធ្វើផែនទី និងការវិភាគអ្នកផ្តល់សេវា/ហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តរតនគិរី
A4.2 ជំនួយបច្ចេកទេសសម្រាប់ការរចនា ប្រព័ន្ធសេវាកម្មទូលំទូលាយ **កុស្ស**(COSS)
A4.3 ការកសាងសមត្ថភាព និងជំនួយបច្ចេកទេសដល់ការចាប់ផ្តើម **កុស្ស**(COSS)
A4.4 សិក្ខាសាលាពង្រឹងសមត្ថភាព ដើម្បីបង្កើនជំនាញរបស់អ្នកផ្តល់សេវាកម្ម និងដោះស្រាយបញ្ហាគម្លាតនៃប្រព័ន្ធសេវាកម្ម
A4.5 ការចាប់ផ្តើម **កុស្ស**(COSS) និងការផ្តល់ជំនួយហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់ **កុស្ស**(COSS) ដែលបានជ្រើសរើស (ជំនួយផ្នែកហិរញ្ញវត្ថុដល់ភាគីទីបី)

**ចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ ស្វាយចន្ទី**

លទ្ធផលដំបូងនៃការវាយតម្លៃប្រើប្រាស់វិធីសាស្ត្រ **រេស្កូ**(RESCO) គឺការកំណត់ចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃស្វាយចន្ទីដែលត្រូវសម្រេចនៅឆ្នាំ 2030 រួមទាំង "ការបង្កើនការលក់គ្រាប់ស្វាយចន្ទីនៅលើទីផ្សារជាតិ និងអន្តរជាតិរហូតដល់ 30% តាមរយៈការជំរុញការផលិតផលិតផលគ្រាប់ស្វាយចន្ទី និងផលិតផលកែច្នៃពីគ្រាប់ស្វាយចន្ទី ដោយពឹងផ្អែកលើគុណសម្បត្តិប្រកួតប្រជែងរបស់វា ដូចជាលក្ខណៈសរីរាង្គ និងតម្លៃដែលមិនប៉ះពាល់ដល់បរិស្ថាន"។ ជាក់ស្តែង គ្រាប់ស្វាយចន្ទីខេត្តរតនគិរីត្រូវបានគេកោតសរសើរចំពោះរសជាតិដ៏ពិសេសរបស់វា - ក្រែមទឹកដោះគោ(ខ្ទិះ និងមានរស់ជាតិឆ្ងាញ់) ឈ្ងុយ - ផ្តល់អារម្មណ៍ចង់ញុំាកាន់តែច្រើនឡើង - ដែលគុណភាពត្រូវបានធានាដោយការយកចិត្តទុកដាក់ពីសំណាក់ការធ្វើការងារដោយដៃដ៏ឈ្លាសវៃរបស់កសិករ និងការមិនប្រើជីគីមី។

សរុបមក ការផលិតស្វាយចន្ទីភាគច្រើនក្នុងខេត្តរតនគិរីមិនប្រើសារធាតុគីមីទេ ដោយសារដីមានគុណភាពល្អ។ ជាពិសេសពូជបុរាណ/ប្រពៃណីត្រូវបានដាំដុះដោយមិនប្រើជីគីមី ផលិតផលនេះគឺល្អសម្រាប់សុខភាព។ ចំពោះពូជ 09 និង M-23 គឺមិនអាចធានាបាន 100% ទេថាការផលិតនេះមិនប្រើជី និងសារធាតុគីមី។ នេះអាស្រ័យលើធម្មជាតិនៃដី។ សម្រាប់តំបន់ដែលដីមិនមានជីជាតិគ្រប់គ្រាន់ កសិករត្រូវប្រើទាំងជីធម្មជាតិ និងជីគីមី។

ការងារភាគច្រើនគឺធ្វើដោយដៃ (អនុវត្តក្នុងមូលដ្ឋាន) ដែលធានាការយកចិត្តទុកដាក់បន្ថែមទៀតចំពោះគុណភាពនៃផលិតផល និងម្យ៉ាងវិញទៀត ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ លើសពីនេះទៅទៀត ក៏មានការកើនឡើងផងដែរនូវការអនុវត្តដែលមិនប៉ះពាល់ដល់បរិស្ថាន ដោយផ្អែកលើការកែច្នៃសំណល់តម្លៃជាចម្បង។

## ៥.៣. គោលការណ៍ណែនាំជាយុទ្ធសាស្រ្ត និងផែនការសកម្មភាពលម្អិត

គោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់សកម្មភាពត្រូវបានពិពណ៌នាដោយយោងទៅលើ៖

- អាទិភាព ដូចដែលបានកំណត់កាលពីមុន
- ផែនការយុទ្ធសាស្រ្ត៖ អភិបាលកិច្ច សេវាកម្ម និងការកសាងសមត្ថភាព

ហើយពួកគេត្រូវបានបែងចែកទៅជា៖

⇨ សកម្មភាពនៅខ្សែសង្វាក់តម្លៃច្រើនកម្រិត(AM) ដែលរួមបញ្ចូលសកម្មភាពដែលមានលក្ខណៈទូទៅសម្រាប់ខ្សែសង្វាក់តម្លៃទាំងអស់។

⇨ សកម្មភាពនៅកម្រិតខ្សែសង្វាក់តម្លៃជាក់លាក់នៃខ្សែសង្វាក់តម្លៃ ស្វាយចន្ទី

| អាទិភាពលេខ ១ |
| --- |

### ខ្សែសង្វាក់តម្លៃច្រើនកម្រិត

AM1.1៖ **អភិបាលកិច្ច**

AM1.11៖ បង្កើតវេទិកា **ផ្លាសិដ**(PLASED) (វេទិកាសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព) ដែលជាយន្តការសម្រាប់ពង្រឹងការសន្ទនាក្នុងសង្គម និងការរក្សាបាននូវអត្ថប្រយោជន៍ប្រកួតប្រជែង និងការបង្កើតការងារ តាមរយៈការផ្តល់ជំនួយបច្ចេកទេសក្នុងការរចនា និងការចាប់ផ្តើមវេទិកា **ផ្លាសិដ**(PLASED)។

សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP2 (A.21)

AM.12: គាំទ្រសកម្មភាពអាទិភាព ដូចជា៖

a) សេចក្តីព្រាងនៃយុទ្ធសាស្រ្តទីផ្សារ
b) ការសហការណ៍ជាមួយរដ្ឋាភិបាលសម្រាប់ការធ្វើឲ្យប្រសើរឡើងនូវការអនុវត្តផែនការរបស់រដ្ឋាភិបាល និងគាំទ្រសហគ្រាសធុនតូច និងមធ្យម(SMMEs) ដែលចង់រីកចម្រើន និងមានលក្ខណៈផ្លូវការ។
c) គាំទ្រការកសាងសម្ព័ន្ធភាពជាមួយតួអង្គជាតិ និងអន្តរជាតិដែលពាក់ព័ន្ធផ្សេងទៀត។

សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP2 (A.22)

DRAFT

AM1.13៖ ការបោះពុម្ព និងផ្សព្វផ្សាយកូនសៀវភៅស្តីពីបទពិសោធន៍របស់វេទិកា **ផ្លាសិដ**(PLASED)
សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP2 (A.23)

AM1.2៖ **សេវាកម្ម**

AM1.21 បង្កើត ប្រព័ន្ធសេវាកម្មទូលំទូលាយ (COSS) សម្រាប់ការផ្តល់សេវាសេដ្ឋកិច្ច-សង្គមប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល តាមរយៈការគូសផែនទី និងការវិភាគអ្នកផ្តល់សេវា/ហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តរតនគិរី។

សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP4 (A4.1)

AM1.22៖ ជំនួយបច្ចេកទេសសម្រាប់ការរចនា ប្រព័ន្ធសេវាកម្មទូលំទូលាយ **កុស្ស**(COSS)
សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP4 (A4.2)

AM1.23៖ គាំទ្រដល់ការចាប់ផ្តើម ប្រព័ន្ធសេវាកម្មទូលំទូលាយ **កុស្ស**(COSS)
សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP4 (A4.3)

AM1.24៖ ការផ្តល់ជំនួយហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់**កុស្ស**(COSS) ដែលបានជ្រើសរើស(ជំនួយផ្នែកហិរញ្ញវត្ថុដល់ភាគីទីបី)
សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP4 (A4.5)

AM1.25៖ ធ្វើអោយប្រសើរឡើងនូវសេវាកម្មអាជីវកម្ម និងការចូលប្រើប្រាស់ពួកវា ដោយផ្តល់អាទិភាពដល់សេវាកម្មដូចខាងក្រោម៖

- សេវាបច្ចេកទេស រដ្ឋបាល អង្គការ/ស្ថាប័ន
- ការធ្វើទីផ្សារ/ពាណិជ្ជកម្ម
- គាំទ្រក្នុងការអភិវឌ្ឍន៍សហករណ៍ កិច្ចសហប្រតិបត្តិការ/បណ្តាញទំនាក់ទំនង
- គាំទ្រក្នុងការអភិវឌ្ឍន៍សម្ព័ន្ធភាព/សមាគម

សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP4 (A44)

AM1.3៖ **ការកសាងសមត្ថភាព**

AM1.31៖ កសាងសមត្ថភាពលើការគ្រប់គ្រងអាជីវកម្ម និងការធ្វើផែនការអាជីវកម្ម មានប្រយោជន៍ផងដែរសម្រាប់ការស្នើសុំសំណើថវិកា និងឥណទាន។
សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP4 (A14)

DRAFT

<u>A1 – **ខ្សែសង្វាក់តម្លៃស្វាយចន្ទី**</u>

A1.1 **អភិបាលកិច្ច**

A1.11៖ បង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃស្វាយចន្ទី ដោយឈរលើមូលដ្ឋាននៃអ្នកចូលរួមក្រុមស្នូល និងជាក្រុមរងរបស់វេទិកា **ផ្លាសិដ**(PLASED) ដែលមានភារកិច្ចដូចខាងក្រោម៖

a) បង្កើតគំនិតផ្តួចផ្តើមនានា សម្រាប់ការអភិរក្សប្រព័ន្ធអេកូឡូស៊ី ជាចម្បងទាក់ទងនឹងជីវជាតិរបស់ដី (ការអនុវត្តការស្តារឡើងវិញនូវគុណភាពដី ដូចជា (ក)៖ រចនាសម្ព័ន្ធរបស់វា (សមាសធាតុគីមីនៃដី និងសារធាតុរ៉ែ) ការបង្រួមរបស់វា (អត្រាជ្រៀតចូលនៃទឹក ស្ថេរភាពនៃការប្រមូលផ្តុំដី) រយៈពេលដែលមិនបានដាំដំណាំក្នុងមួយឆ្នាំ; ភាគរយអប្បបរមានៃដីស្រែ/ចំការដែលមានដំណាំ
b) ការសម្រួលដល់ការធ្វើពាណិជ្ជកម្ម (*អាចតាមរយៈការជួលសហករណ៍ឯកទេស*) តាមរយៈ៖
   • យុទ្ធសាស្ត្រទីផ្សាររបស់ខ្សែសង្វាក់តម្លៃ រួមទាំងគោលនយោបាយម៉ាកយីហោ ការផ្សាយពាណិជ្ជកម្ម
   • ការលើកកម្ពស់ការទិញរួម និងការប្រើប្រាស់គ្រឿងចក្រដែលមានតំលៃថ្លៃ ដើម្បីកាត់បន្ថយការចំណាយ (លាងសម្អាត ស្ងោរ បកសំបក។ល។);
   • បង្កើនសមត្ថភាពចរចាជាមួយអ្នកលក់ដុំ ហាង ផ្សារ ផ្សារទំនើប ខ្សែសង្វាក់ពាណិជ្ជកម្ម
c) ការសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងថ្នាក់ជាតិដើម្បីសម្រេចបាននូវប្រព័ន្ធព័ត៌មានដែលអាចចូលប្រើប្រាស់បាន ឬទទួលបាននូវព័ត៌មានទាក់ទងនឹងវិធានការជាតិ ដើម្បីគាំទ្រខ្សែសង្វាក់តម្លៃ និងការណែនាំការលើកទឹកចិត្ត ឬវិធានការណ៍ថ្នាក់ជាតិ ដើម្បីគាំទ្រខ្សែសង្វាក់តម្លៃ ជាពិសេសទៅលើការចាប់ផ្តើមអាជីវកម្ម និងយន្តការហិរញ្ញវត្ថុជាក់លាក់។
d) ការភ្ជាប់តួអង្គនៃខ្សែសង្វាក់តម្លៃស្វាយចន្ទីជាមួយបណ្តាញអន្តរជាតិនានាទាក់ទងនឹងបច្ចេកវិទ្យាសម្រាប់បច្ចេកវិទ្យាថ្មីៗ។

សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP2 (A2.2)

A1.2៖ **ការកសាងសមត្ថភាព**

A1.21៖ កសាងសមត្ថភាពបច្ចេកទេស និងសហគ្រិន ដើម្បីជំរុញការអនុវត្តការស្តារឡើងវិញនូវគុណភាពដី និងរក្សាការគ្រប់គ្រងបរិស្ថានល្អ ដើម្បីទាញប្រយោជន៍ពីបរិស្ថានមកប្រើប្រាស់ ដូចជាជីសរីរាង្គមួយចំនួន និងប្រយោជន៍ផ្សេងទៀត។

សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP1 (A1.4)

A1.23៖ ពង្រឹងសមត្ថភាពរបស់សហគ្រិនទៅលើ៖

- ការធ្វើទីផ្សារ និងការធ្វើពាណិជ្ជកម្ម (ជាលក្ខណៈបុគ្គល និងសមូហភាព)
- រក្សាបាននូវចំណេះដឹងបែបប្រពៃណីក្នុងការផលិតពូជក្នុងស្រុក

DRAFT

សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP4 (A4.3)

A1.24៖ ធ្វើអោយប្រសើរឡើងនូវសមត្ថភាពអ្នកផ្តល់សេវាកម្ម ជាពិសេសទៅលើ៖

- ការគាំទ្រដល់ការចាប់ផ្តើមអាជីវកម្ម ជាពិសេសគឺសំដៅទៅលើស្រ្តី និងយុវជន
- ការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោង ឧទាហរណ៍ សមត្ថភាពដែលអនុញ្ញាតឱ្យពួកគេសម្រេចបាននូវលក្ខខណ្ឌសម្រាប់សិទ្ធិ និងឱកាសដើម្បីទទួលបានមូលនិធិពីស្ថាប័នឯកជន និងសាធារណៈ ទាំងថ្នាក់ជាតិ និងអន្តរជាតិ។
- សេវាបច្ចេកទេស រដ្ឋបាល អង្គភាព/ស្ថាប័ន
- សេវាកម្មពាណិជ្ជកម្ម និងទីផ្សារ
- គាំទ្រការផ្ទេរ ឬផ្តល់ជូនបច្ចេកវិទ្យាថ្មីៗ

សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP4 (A4.3)

A1.3 **សេវាកម្ម**

A1.31 ធ្វើអោយប្រសើរឡើងនូវសេវាកម្មអាជីវកម្ម និងលទ្ធភាពទទួលបាន ឬចូលប្រើបាស់សេវាទាំងនោះ (តាមរយៈការបណ្តុះបណ្តាលផងដែរ) តាមរយៈការសម្របសម្រួលអ្នកផ្តល់សេវា ដោយផ្តល់អាទិភាពដល់សេវាកម្មដូចខាងក្រោម៖

a) ការធ្វើទីផ្សារ/ពាណិជ្ជកម្ម (ការផ្សព្វផ្សាយពូជប្រពៃណី/ក្នុងស្រុក តាមរយៈគោលនយោបាយម៉ាកយីហោ ការផ្សាយពាណិជ្ជកម្ម ការដាក់ស្លាក ការតាមដាន និងនិងការទទួលស្គាល់ដោយផ្អែកលើទីតាំងភូមិសាស្រ្ត); តាមរយៈសេវាផ្តល់ព័ត៌មានត្រឹមត្រូវនៅលើទីផ្សារ (និន្នាការ/ការនិយម ដៃគូប្រកួតប្រជែង ឱកាស)
b) សេវាបច្ចេកទេស រដ្ឋបាល អង្គភាព/ស្ថាប័ន
c) ព័ត៌មាន និងសេវាកម្មជំនួយទាក់ទងនឹងបច្ចេកវិទ្យាថ្មីៗ
d) ព័ត៌មាន និងការគាំទ្រទាក់ទងនឹងសេវាកម្មហិរញ្ញវត្ថុ
e) សេវាកម្មគាំទ្រដើម្បីបង្កើតសហករណ៍ បណ្តាញ សម្ព័ន្ធ/សមាគម

សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP4 (A4.4)

A.1.32៖ ផ្តល់សេវាកម្មចាប់ផ្តើមអាជីវកម្ម ជាពិសេសសម្រាប់ការចាប់ផ្តើមសហគ្រាសថ្មីសម្រាប់ការផលិតផលិតផលគ្រាប់ស្វាយចន្ទី និងផលិតផលកែច្នៃពីគ្រាប់ស្វាយចន្ទី៖

- គ្រាប់ស្វាយចន្ទីប្រៃ , គ្រាប់ស្វាយចន្ទីលីង/ដុត; ស្វាយចន្ទីស្ងួត; និងផលិតផលអាហារផ្សេងៗទៀត
- ទឹកស្វាយចន្ទី
- ដំណាប់, ចាហួយ, ទឹកជ្រលក់; ប្រេងឆា, ម្សៅគ្រាប់ស្វាយចន្ទី; ប៊ីរធ្វើពីគ្រាប់ស្វាយចន្ទី; គ្រាប់ស្វាយចន្ទីសរីរាង្គ; អាហារសម្រន់ គ្រាប់ស្វាយចន្ទី និងផ្លែឈើស្ងួតលាយចូលគ្នា(សម្រាប់បរិភោគ)

- ផលិតផលពីសំបកគ្រាប់ស្វាយចន្ទីសម្រាប់ផលិតវ៉ារនីសVanish(*ថ្នាំលាបឈើម្យ៉ាង*), ទឹកថ្នាំបោះពុម្ព, ថ្នាំលាបសម្រាប់សម្ភារៈអ៊ីសូឡង់ និងដើម្បីរក្សាសំណើមនៅក្នុងទូក និងឧបករណ៍នេសាទ, សម្រាប់ការពារឈើ ផ្លាស្ទិច ហ្វ្រាំង និងផលិតផលផ្សេងៗទៀត។ អាល់ម៉ុនសម្រាប់ការប្រើប្រាស់ឧស្សាហកម្មក្នុងការផលិតគ្រឿងសំអាង។
- ផលិតផលពីគ្រាប់ស្វាយចន្ទី ប្រើក្នុងដំណើរការជាឥន្ធនៈសម្រាប់ចម្អិនគ្រាប់ស្វាយចន្ទី។ សំបកឈើ និងស្លឹកប្រើសម្រាប់ធ្វើឱសថ។

សកម្មភាពនេះឆ្លើយតបទៅនឹងសកម្មភាពរបស់គម្រោង **ខ្លេស៊ីដ្រា**(CLESIDRA) នៃផែនការការងារ WP4 (A4.5)

| **អាទិភាពលេខ ២** |
|---|

<u>AM **ខ្សែសង្វាក់តម្លៃច្រើនកម្រិត**</u>

AM2.2៖ **សេវាកម្ម**

AM2.21៖ សម្រេចបាននូវសេវាកម្មដែលឆ្លើយតបទៅនឹងតម្រូវការការងារ និងការផ្គត់ផ្គង់ការងារ

<u>**ខ្សែសង្វាក់តម្លៃគ្រាប់ស្វាយចន្ទី**</u>

A2.1៖ **អភិបាលកិច្ច**

A2.11៖ ផ្តល់អាទិភាពដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ

A2.12៖ គាំទ្របរិយាប័ន្នសង្គម តាមរយៈការសហការណ៍ជាមួយរដ្ឋាភិបាលជាតិសម្រាប់៖

a) ធ្វើឲ្យប្រសើរឡើងនូវសមភាពយេនឌ័រ តាមរយៈ៖
   - ណែនាំវិធានការផ្សះផ្សា និងសម្ភារៈបរិក្ខាររវាងគ្រួសារ និងទំនួលខុសត្រូវការងារ។
   - ការបង្កើនកន្លែងថែទាំសាធារណៈសម្រាប់កុមារ និងមនុស្សចាស់ ឲ្យបានគ្រប់គ្រាន់ និងឆ្លើយតបទៅនឹងតម្រូវការ។

b) ការសម្របសម្រួលលទ្ធភាពទទួលបានកម្លាំងពលកម្ម(ការងារ)សម្រាប់មនុស្សដែលមានសមត្ថភាពរាងកាយ និងផ្លូវចិត្តខុសៗគ្នា។

c) ការណែនាំ/ធ្វើឲ្យប្រសើរឡើងនូវការលើកទឹកចិត្ត/កម្មវិធីដែលគាំទ្រដល់ជីវភាពរស់នៅរបស់ក្រុមជាក់លាក់នៅក្នុងសហគមន៍។

d) ការណែនាំអំពីការលើកទឹកចិត្តសម្រាប់ការធ្វើការងារផ្លូវការ (មិនថាជាលក្ខណៈសមូហភាព ឬបុគ្គល) និងបទប្បញ្ញត្តិដើម្បីប្រយុទ្ធប្រឆាំងនឹងការងារក្រៅផ្លូវការ

A2.13: ធ្វើឲ្យប្រសើរឡើងនូវផ្លូវថ្នល់ ការផ្គត់ផ្គង់អគ្គិសនី និងទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ។

A2.14៖ ការសហការណ៍ជាមួយរដ្ឋាភិបាលដើម្បីធ្វើឲ្យប្រសើរឡើងនូវ៖

a) ប្រសិទ្ធភាពនៃគោលនយោបាយ និងបទប្បញ្ញត្តិសាធារណៈស្តីពីនិរន្តរភាពបរិស្ថាន និងសេដ្ឋកិច្ចបៃតង ជាពិសេសទាក់ទងនឹង៖
   - កាត់បន្ថយការបំពុល (ខ្យល់ ទឹក ដី និងសំឡេង)
   - ការកំណត់កម្រិតនៃការបំភាយឧស្ម័ន តម្លៃសរីរាង្គ។

DRAFT

- ការប្រើប្រាស់ថាមពលជំនួស(ថាមពលកកើតឡើងវិញ)
- ការផ្លាស់ប្តូរទៅកាន់(សម្រេចបាននូវ)បរិស្ថានស្អាត និងការគ្រប់គ្រងកាកសំណល់ ការអនុវត្តប្រកបដោយនិរន្តរភាព

b) ធ្វើឲ្យប្រសើរឡើងនូវយន្តការឆ្លើយតបសម្រាប់ការប្រឈមមុខនឹងភាពអាសន្ន រួមមាន៖
- ប្រព័ន្ធជូនដំណឹង ឬផ្តល់ព័ត៌មានប្រកបដោយប្រសិទ្ធភាព និងឥតគិតថ្លៃ (WhatsApp, សង្គម, រថយន្តចល័ត, វិទ្យុ, ទូរទស្សន៍។ល។)
- ការធ្វើតេស្តពីមុនលើឥរិយាបទបុគ្គល និងសមូហភាព
- ការផ្តល់ជូននូវកញ្ចប់មូនិធិសាធារណៈសម្រាប់ស្ថានភាពអាសន្ន
- ការផ្តល់ជូននូវយន្តការធានារ៉ាប់រង
- ការផ្តល់ជូននូវជំនួយសង្គ្រោះបន្ទាន់ផ្នែកថែទាំសុខភាព និងថ្នាំពេទ្យ
- ការផ្តល់ជូននូវកន្លែងស្នាក់នៅ និងលំនៅដ្ឋានបណ្តោះអាសន្ន។

A2.15: ការរៀបចំអង្គការដែលផ្តល់ជំនួយទៅវិញទៅមក; វត្តមានរបស់ក្រុមសង្គ្រោះស្ម័គ្រចិត្តដែលត្រូវបានបណ្តុះបណ្តាល

A2.16៖ ការសម្រួលដល់ការធ្វើពាណិជ្ជកម្ម (អាចតាមរយៈការជួលសហករណ៍ឯកទេស - ការជួលអ្នកឯកទេសឲ្យធ្វើការឲ្យ) រួមមាន៖
- ការចែករំលែកយុទ្ធសាស្ត្រទីផ្សាររបស់ខ្សែសង្វាក់តម្លៃ រួមទាំងគោលនយោបាយម៉ាកយីហោ ការផ្សាយពាណិជ្ជកម្ម
- កាត់បន្ថយអំណាចឈ្មួញកណ្តាល
- បង្កើតបណ្តាញទិញតាមអ៊ីនធឺណិត និងតាមទូរស័ព្ទ
- សម្របសម្រួលការរៀបចំគំនិតផ្តួចផ្តើមប្រចាំឆ្នាំយ៉ាងហោចណាស់១ដង (ពិព័រណ៍ ពិធីបុណ្យ ព្រឹត្តិការណ៍វប្បធម៌ ។ល។) សម្រាប់ការផ្សព្វផ្សាយផលិតផលស្វាយចន្ទីដែលគាំទ្រដល់ឱកាសនៃការរៃអង្គាសប្រាក់ (ឱកាសពីទីភ្នាក់ងារអន្តរជាតិ ការឧបត្ថម្ភ ការផ្តល់មូលនិធិ និងទំនួលខុសត្រូវសង្គមរបស់អាជីវកម្ម)។
- ការផ្សព្វផ្សាយក្នុងចំណោមអង្គភាពសាធារណៈនូវការទិញផលិតផលគ្រាប់ស្វាយចន្ទីក្នុងស្រុក
- ការសម្របសម្រួលលទ្ធភាពក្នុងទទួលបានការធ្វើពាណិជ្ជកម្មដោយយុត្តិធម៌

A2.17: លើកកម្ពស់សហករណ៍សហគ្រិនភាព (សហករណ៍សហគ្រិនភាព សំដៅលើអង្គការ ឬក្រុមហ៊ុនដែលមានសហគ្រិនជាច្រើនធ្វើការរួមគ្នាដើម្បីផលប្រយោជន៍អ្វីមួយ)

A2.18: ធ្វើកិច្ចព្រមព្រៀងជាមួយសាកលវិទ្យាល័យ និងសាលាវិជ្ជាជីវៈ សម្រាប់ការរៀបចំជំនាញវិជ្ជាជីវៈថ្មីៗ ដោយផ្តល់អាទិភាពទៅលើជំនាញការគ្រប់គ្រងពូជ, ជំនាញភាពជាអ្នកដឹកនាំ; ការកែច្នៃផលិតផលពីផ្លែឈើស្រស់; ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំបក(គ្រាប់ស្វាយចន្ទី), ផលិតផលផលិតចេញពីកាកសំណល់ និងសំណល់រុក្ខជាតិ។

DRAFT

A2.19៖ គាំទ្រដល់និរន្តរភាពបរិស្ថាន សេដ្ឋកិច្ចបៃតង និងសេដ្ឋកិច្ចជារង្វង់តាមរយៈ៖

a) ការបង្កើតយន្តការបញ្ជាក់គុណភាព (វិញ្ញាបនប័ត្របញ្ជាក់គុណភាព) សម្រាប់តម្លៃគ្រាប់ស្វាយចន្ទីសរីរាង្គ
b) ជំរុញសេដ្ឋកិច្ចជារង្វង់តាមរយៈ៖

- ការលើកកម្ពស់ទំនាក់ទំនងរវាងអ្នកផលិត និងអ្នកស្រាវជ្រាវ ដើម្បីច្នៃប្រឌិតការអនុវត្តសេដ្ឋកិច្ចជារង្វង់។
- ធ្វើកិច្ចព្រមព្រៀងជាមួយសាកលវិទ្យាល័យ និងមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) សម្រាប់ការណែនាំវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈក្នុងវិស័យសេដ្ឋកិច្ចជារង្វង់។

A2.20៖ ជំរុញការច្នៃប្រឌិតថ្មីក្នុងខ្សែសង្វាក់តម្លៃស្វាយចន្ទី ជាពិសេសការសម្របសម្រួល/ធ្វើឲ្យប្រសើរឡើងនូវការស្រាវជ្រាវក្នុងវិស័យអភិរក្សគ្រាប់ពូជ ជំងឺរុក្ខជាតិ ដើម្បីការពារការខូចខាតដល់វិស័យកសិកម្ម។
A2.21៖ ការបណ្តុះបណ្តាលបុគ្គលិកដែលមានជំនាញទាបលើដំណើរការផលិតគ្រាប់ស្វាយចន្ទីទាំងមូល ដូចជា ការលាងសម្អាត ការស្ងោរ ការបកគ្រាប់ស្វាយចន្ទី ។ល។

A2.2 **ការកសាងសមត្ថភាព**

A2.21៖ ធ្វើឱ្យប្រសើរឡើងនូវជំនាញវិជ្ជាជីវៈ ដែលអាចធ្វើទៅបានតាមរយៈគំនិតផ្តួចផ្តើមដូចជា "សាកលវិទ្យាល័យវិជ្ជាជីវៈ" និងការបង្ហាញពីការអនុវត្តប្រកបដោយភាពច្នៃប្រឌិត ដោយយោងជាពិសេសទៅលើ៖

a) រដ្ឋបាល/ការគ្រប់គ្រង, លទ្ធកម្ម(ការទិញ)ផលិតផល និងការធ្វើទីផ្សារ, ការដឹកជញ្ជូន និងការរក្សាទុក/ទុកដាក់(ក្នុងឃ្លាំង)។
b) ប្រតិបត្តិករនៃបច្ចេកវិទ្យា ឌីជីថល និងឧបករណ៍ចាប់សញ្ញាពីចម្ងាយថ្មី; មនុស្សយន្តនិងស្វ័យប្រវត្តិកម្ម; អ្នកជំនាញផ្នែកបញ្ញាសិប្បនិម្មិត (AI)
    - ជួយសម្រួលដល់វគ្គបណ្តុះបណ្តាលសម្រាប់ប្រតិបត្តិករនៃបច្ចេកវិទ្យា ឌីជីថល និងឧបករណ៍ចាប់សញ្ញាពីចម្ងាយ, អ្នកជំនាញបច្ចេកទេសផ្នែកមនុស្សយន្ត និងស្វ័យប្រវត្តិកម្ម, អ្នកជំនាញផ្នែកបញ្ញាសិប្បនិម្មិត (AI)

A2.22៖ ធ្វើអោយប្រសើរឡើងនូវសមត្ថភាពរបស់សហគ្រិន ជាពិសេសទៅលើ៖

- ការគ្រប់គ្រងពូជ
- ជំនាញភាពជាអ្នកដឹកនាំ
- បច្ចេកវិទ្យាថ្មីៗទាក់ទងនឹងខ្សែសង្វាក់តម្លៃស្វាយចន្ទី
- សេដ្ឋកិច្ចជារង្វង់ ដូចជា៖ ការអនុវត្តដំណោះស្រាយសម្រាប់តម្លៃ(ការផលិត)ដែលមិនប៉ះពាល់ដល់បរិស្ថាន, ការប្រើប្រាស់សម្ភារៈដែលអាចកែច្នៃឡើងវិញបាន; ការអនុវត្តប្រកបដោយនិរន្តរភាពនៃការគ្រប់គ្រងសំណល់ [ប្រើប្រាស់ឡើងវិញនូវកាកសំណល់របស់ខ្លួន និងការប្រើប្រាស់ទឹកសំណល់(ទឹកដែលប្រើរួចហើយ)ឡើងវិញ] និងចាប់ផ្តើមអាជីវកម្មទាក់ទងនឹងការប្រមូលសំរាម បែងចែកសំរាម ការរក្សាទុក និងការកែច្នៃឡើងវិញ។

A2.23៖ ការផ្តល់វគ្គបណ្តុះបណ្តាលទៅដល់អ្នក/មនុស្សដែលមានសមតភាពរាងកាយ និងផ្លូវចិត្តខុសៗគ្នាដើម្បីឲ្យពួកគេអាចទទួលបានឱកាសការងារ។

A2.24៖ បង្កើនសមត្ថភាពសម្រាប់ការចូលទៅក្នុងបណ្តាញអន្តរជាតិនៃការធ្វើពាណិជ្ជកម្មដោយយុត្តិធម៌ (Fair trade)។

A2.25៖ ផ្តល់ការកសាងសមត្ថភាពជាក់លាក់ដែលអនុគ្រោះដល់ស្ត្រីឱ្យទទួលបានតំណែងជាអ្នកដឹកនាំ

A2.26៖ អនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹង (អាចតាមរយៈសន្និសីទនានា) ដើម្បី៖

a) ពង្រឹងនិរន្តរភាពបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ដោះស្រាយជូនប្រជាពលរដ្ឋលើបញ្ហាដូចខាងក្រោម៖
   - សារៈសំខាន់នៃកសិកម្មឆ្លាតវៃ និងអត្ថប្រយោជន៍របស់វា។
   - សារៈសំខាន់នៃសេដ្ឋកិច្ចជារង្វង់ ចាប់ផ្តើមពីការអនុវត្តប្រកបដោយនិរន្តរភាពនៃការគ្រប់គ្រងសំណល់ (ដូចជាការប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ) និងតម្លៃសរីរាង្គ (ការផលិតបែបសរីរាង្គ)
   - ការធ្វើឲ្យប្រសើរឡើងនូវឧបករណ៍ត្រួតពិនិត្យបរិស្ថាន

b) ពង្រឹងនិរន្តរភាពសង្គម ជាពិសេសទៅលើបញ្ហាដូចខាងក្រោម៖
   - សារៈសំខាន់របស់ស្ត្រីក្នុងការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ
   - ឱកាសអាជីវកម្ម និងការងារ ដែលផ្តល់អាទិភាពដល់ជនពិការ ស្ត្រី និងយុវជន ដែលបង្កើតឡើងដោយការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ។
   - សារៈសំខាន់ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ។

A2.3 **សេវាកម្ម**

A2.31៖ ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មសម្រាប់និរន្តរភាពសង្គម ពិសេសទៅលើ៖

- គាំទ្រសហគ្រាសដែលប្រើប្រាស់ទំនួលខុសត្រូវសង្គមរបស់ពួកគេសម្រាប់ការវិនិយោគសង្គម។
- ជួយសម្រួលដល់សហគ្រាសធុនតូច និងមធ្យម ដែលគ្រប់គ្រងដោយយុវជនអាយុក្រោម ៣៥ឆ្នាំ
- បង្កើតការងារសម្រាប់ជនមានពិការភាព (ផ្លូវចិត្ត និង/ឬរាងកាយ)។
- បង្កើតការងារសម្រាប់អ្នកដែលមានជំនាញវិជ្ជាជីវៈទាប ។
- ការលើកកម្ពស់សេវាកម្មផ្តល់ព័ត៌មានអំពីឱកាសវគ្គបណ្តុះបណ្តាលដែលមានស្រាប់

A2.32៖ ធ្វើឲ្យប្រសើរឡើងនូវសេវាកម្មសម្រាប់និរន្តរភាពបរិស្ថាន ជាពិសេសទៅលើ៖

- ការលើកកម្ពស់ការបង្កើតការបណ្តុះគ្រាប់ពូជដើម្បីអភិរក្សពូជស្វាយចន្ទីក្នុងស្រុក។
- បញ្ចូល ឬចូលរួមជាមួយសាកលវិទ្យាល័យ ដើម្បីរួមបញ្ចូលបញ្ហាទាក់ទងនឹងការការពារបរិស្ថាននៅក្នុងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ។
- សម្រួលសេវាត្រួតពិនិត្យ/គ្រប់គ្រងការបំពុលក្នុងខេត្តរតនគិរី។

- ការបង្កើនចំនួនក្រុមហ៊ុនកែច្នៃកាកសំណល់រឹង ក្រុមហ៊ុនកែច្នៃកាកសំណល់សរីរាង្គ និងក្រុមហ៊ុនកែច្នៃកាកសំណល់រាវ។
- បង្កើតទំនាក់ទំនងរវាងគ្រឹះស្ថានសិក្សាក្នុងស្រុក និងបណ្តាញអន្តរជាតិសម្រាប់ការរៀនសូត្រពីការអនុវត្តល្អបំផុត។
- ការលើកកម្ពស់ការដំឡើង និងថែទាំឧបករណ៍ថាមពលកកើតឡើងវិញ។

## អាទិភាពលេខ ៣

## ខ្សែសង្វាក់តម្លៃស្វាយចន្ទី

A3.1៖ **អភិបាលកិច្ច**

A3.11៖ ការសហការណ៍ជាមួយរដ្ឋាភិបាលសម្រាប់៖

- បង្កើនកម្រិតនៃការយកចិត្តទុកដាក់ចំពោះតម្រូវការសង្គម ដោយផ្តល់អាទិភាពទៅលើការធ្វើអោយប្រសើរឡើងនូវយុទ្ធសាស្ត្រ/គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ, ណែនាំវិធានការ និងការលើកទឹកចិត្តសម្រាប់ការងារសម្រាប់ស្ត្រី។
  - ធ្វើអោយប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងនឹងខ្សែសង្វាក់តម្លៃ ជាពិសេសទាក់ទងនឹង៖ ហេដ្ឋារចនាសម្ព័ន្ធទឹក និងការផ្គត់ផ្គង់ទឹក, ពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងការផ្គត់ផ្គង់អគ្គិសនីក្នុងខេត្តទាំងមូល, អនុញ្ញាតឱ្យចូលប្រើប្រាស់ធនធានសាធារណៈ (ទន្លេ ដី ។ល។), និងលទ្ធភាពទទួលបានធនធានឯកជន (ទ្រព្យសម្បត្តិដីធ្លី)។
  - ការណែនាំអំពីយន្តការហិរញ្ញវត្ថុសម្រាប់ការផលិតគ្រាប់ស្វាយចន្ទី រួមទាំងការលើកទឹកចិត្តសម្រាប់ការទទួលបាននូវឧបករណ៍ដូចជា៖ "Autoclave - ឆ្នាំងចំហុយ/ចម្អិន" ដែលប្រើសម្រាប់ចម្អិនគ្រាប់ពូជ/គ្រាប់ចន្ទី, ចង្ក្រាន; ធ្នើរសម្រាប់ហាលឲ្យត្រជាក់; តុប្រើសម្រាប់ចាត់ថ្នាក់ និងខ្ចប់; ម៉ាស៊ីនបូមធូលី; ឧបករណ៍ការពារសុវត្ថិភាព; ម៉ាស៊ីនចុចធារាសាស្ត្រ; ម៉ាស៊ីនបិទគម្របដោយស្វ័យប្រវត្តិ តាមរយៈការបង់ពន្ធត្រឹមត្រូវ និងដោយកាត់បន្ថយនីតិវិធីការិយាធិបតេយ្យ ។
  - សម្របសម្រួលការផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីជាតិ និងវិធានការ បទប្បញ្ញត្តិនានា។

A3.12៖ ធ្វើកិច្ចព្រមព្រៀងជាមួយស្ថាប័នហិរញ្ញវត្ថុដើម្បីកាត់បន្ថយឧបសគ្គនៃការទទួលបានឥណទាន (ការធានា/លក្ខខណ្ឌធានា, ការប្រាក់, រយៈពេលអនុគ្រោះ, ការធានារ៉ាប់រង។ល។)

A3.13៖ លើកកម្ពស់សមភាពយេនឌ័រ តាមរយៈ៖

- រដ្ឋធម្មនុញ្ញ(ច្បាប់/សិទ្ធិ)ស្តីពីសហជីពកម្មករស្ត្រី
- ការបង្កើតប្រព័ន្ធទូរស័ព្ទ សម្រាប់រាយការណ៍ពីការយាយី/ការបៀតបៀន ដែលគ្រប់គ្រងដោយសមាគមស្ត្រី។
- ការសម្របសម្រួលអាជីវកម្មក្រៅផ្លូវការ តាមរយៈការចរចាជាមួយរដ្ឋាភិបាលក្នុងការកាត់បន្ថយបទប្បញ្ញត្តិការិយាធិបតេយ្យ និងការផ្តល់ជូននូវការលើកទឹកចិត្ត

A3.14៖ ទទួលស្គាល់ម៉ាកគ្រាប់ស្វាយចន្ទីខេត្តរតនគិរី ឬយន្តការនៃការទទួលស្គាល់ និងការធានាថាផលិតផលនៅក្រោមស្លាកសញ្ញាគ្រាប់ស្វាយចន្ទី(ខេត្តរតនគិរី) ដែលមានលក្ខណៈអាចទុកចិត្តបានទាក់ទងនឹងគុណភាព អាហារូបត្ថម្ភ ល្អសម្រាប់សុខភាព សង្គម សីលធម៌ បរិស្ថាន។ល។ តាមរយៈការបង្កើតការអនុវត្តអប្បបរមាទាមទារការប្រើ

DRAFT

ប្រាស់ស្លាកសញ្ញា; នីតិវិធីសម្រាប់ការទទួលបានស្លាកសញ្ញា; ប្រព័ន្ធត្រួតពិនិត្យសម្រាប់ការវាយតម្លៃ និងការត្រួតពិនិត្យការអនុវត្តសម្រាប់ការថែរក្សាស្លាកសញ្ញា។

A3.2៖ **ការកសាងសមត្ថភាព**

A3.21៖ ធ្វើឲ្យប្រសើរឡើងនូវជំនាញវិជ្ជាជីវៈទាក់ទងទៅនឹង៖

- សមត្ថភាពរបស់អ្នកផលិតលើការសាបព្រោះ, ប្រព័ន្ធធារាសាស្ត្រ ការគ្រប់គ្រង ភាពធន់នឹងសត្វល្អិត និងជំងឺ, ផលិតភាពនៃការប្រមូលផល ការគ្រប់គ្រងពូជ ស្ថេរភាពនៃការអនុវត្ត។ល។
- ការផ្តល់វគ្គបណ្តុះបណ្តាលអំពីម៉ាកយីហោ និងយុទ្ធសាស្ត្រទីផ្សារក្នុងតំបន់
- ការបណ្តុះបណ្តាលទៅលើការបង្កើនទិន្នផល គុណភាព រួមទាំងការកាត់បន្ថយការខាតបង់ទិន្នផល និងការតាមដាន
- ការបណ្តុះបណ្តាលការងារទៅដល់ស្ត្រីលើខ្សែសង្វាក់តម្លៃស្វាយចន្ទី។

A3.22៖ ធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគ្រិនដូចជា៖

- វគ្គបណ្តុះបណ្តាលស្តីពីការផ្តល់ហិរញ្ញប្បទានអាជីវកម្ម រួមទាំងការស្វែងរកឱកាស (កម្មវិធីជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ សហគ្រាសដែលមានទំនួលខុសត្រូវសង្គម) ការបង្កើតគម្រោង បច្ចេកទេសនៃការអនុវត្ត ការទទួលបានឥណទានពីធនាគារ ការផ្តល់មូលនិធិ។ល។
- ការកសាងសមត្ថភាពទៅលើ សហគ្រិនភាព

A3.23៖ ធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់អ្នកផ្តល់សេវា ទាក់ទងនឹង៖

- សេវាថែទាំឧបករណ៍;
- ការកសាងសមត្ថភាពទាក់ទងនឹងសេវា អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ទៅលើយុទ្ធសាស្ត្រកសាងសមត្ថភាពតួអង្គខ្សែសង្វាក់តម្លៃស្វាយចន្ទី

A3.24៖ ធ្វើអោយប្រសើរឡើងនូវសមភាពយេនឌ័រ តាមរយៈ៖

- ការពង្រឹងសមត្ថភាពរបស់ស្ត្រីសម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាយេនឌ័រ (ការកំណត់(សម្គាល់)បញ្ហា/ហេតុការណ៍, ធ្វើការរាយការណ៍ ឬបរិហារវា, ផ្ទៀងផ្ទាត់ប្រសិនបើវាកើតឡើងចំពោះស្ត្រីផ្សេងទៀត, ដឹងពីច្បាប់ និងសិទ្ធិរបស់ស្ត្រី)
- ការបង្ហាញពីការអនុវត្តល្អបំផុតនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ ឬគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ

A3.25៖ ធ្វើអោយប្រសើរឡើងនូវនិរន្តរភាពបរិស្ថាន តាមរយៈ៖

- ការបណ្តុះបណ្តាលដល់អង្គការ និង/ឬស្ថាប័នដែលប្តេជ្ញាចិត្តចំពោះនិរន្តរភាពបរិស្ថាន និងសេដ្ឋកិច្ចបៃតង។
- ការកសាងសមត្ថភាពទៅកាន់អ្នកផលិតដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល និងទឹក លើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញ និងការអនុវត្តល្អបំផុតក្នុងការគ្រប់គ្រងកាកសំណល់ ដើម្បីជៀសវាងការបំពុលដី និងទឹក ។
- ការកសាងសមត្ថភាពលើវិធានការទប់ទល់ដែលអាចត្រូវបានអនុវត្តដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដូចជា៖ សមត្ថភាពក្នុងការផលិតទំនិញដែលត្រូវការក្នុងគ្រាមានអាសន្នស្បៀងអាហារបន្ទាប់ពីគ្រោះមហន្តរាយ, លទ្ធភាពនៃការប្រើប្រាស់កម្មករដើម្បីគាំទ្រតម្លៃផ្សេងទៀត; ការលុប

DRAFT

បំបាត់ការបំពុលកាកសំណល់ (ផលិតផលគីមី, ផលិតផលដែលមានកាកសំណល់ដែលមិនអាចបំប្លែងបាន); ការកាត់បន្ថយថាមពលពីប្រភពមិនកកើតឡើងវិញ និងការបំភាយឧស្ម័នកាបូនិក ($CO_2$); គំរូដាំដុះបែបសរីរាង្គ និងការដាំដុះបែបកសិអេកូឡូស៊ី ផ្អែកលើបែបផែនផ្សេងៗ ឬភាពចម្រុះ។

A3.26៖ លើកកម្ពស់និរន្តរភាពសង្គម និងបរិស្ថាន តាមរយៈយុទ្ធនាការលើកកម្ពស់ការយល់ដឹងលើបញ្ហាដូចខាងក្រោម៖

- ស្តីពីសមភាពយេនឌ័រ និងសារៈសំខាន់នៃលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការងារ
- ការសម្របសម្រួលសមភាពយេនឌ័រក្នុងការចែកចាយតួនាទី និងសកម្មភាពក្នុងខ្សែសង្វាក់តម្លៃ។
- យុទ្ធនាការលើកកម្ពស់ការយល់ដឹងជាមួយសហគ្រិន រួមទាំងការបៀតបៀនស្ត្រីដែលត្រូវបានហាមឃាត់ និងការធ្វើទុក្ខបុកម្នេញទៅលើស្ត្រីដែលជាបទប្បញ្ញត្តិរបស់ក្រុមហ៊ុន។
- សារៈសំខាន់នៃការរក្សាគុណភាពដី។
- យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់ធនធានទឹករយៈពេលវែងប្រកបដោយប្រសិទ្ធភាព។

A3.3 **សេវាកម្ម**

A3.31៖ ធ្វើអោយប្រសើរឡើងនូវសេវាកម្មអាជីវកម្ម ជាពិសេសសេវាកម្មសម្រាប់សហគ្រិន ដើម្បីបង្កើនភាពប្រកួតប្រជែងនៃខ្សែសង្វាក់តម្លៃ តាមរយៈ៖

- ការលើកកម្ពស់ការបង្កើតសេវាត្រួតពិនិត្យគុណភាព និងវិញ្ញាបនប័ត្រ។
- ការលើកកម្ពស់សេវាសម្រាប់អាជីវកម្ម និងការងារផ្លូវការ
- ការបង្កើតសេវាគាំទ្រដែលមានឯកទេសទាក់ទងនឹងការធ្វើ ឬបង្កើតម៉ាកយីហោ យុទ្ធសាស្ត្រទីផ្សារ យន្តការឃ្លាំមើល និងការនាំយកផលិតផលចូលក្នុងទីផ្សារអន្តរជាតិ។
- ការលើកកម្ពស់សេវាកម្មគាំទ្រដែលមានឯកទេសក្នុងការបង្កើនទិន្នផល គុណភាព រួមទាំងការកាត់បន្ថយការខាតបង់ទិន្នផល និងការតាមដាន
- ការធ្វើអោយប្រសើរឡើងនូវសេវា អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)
- ការធ្វើអោយប្រសើរឡើងនូវសេវាព័ត៌មានទាក់ទងនឹងកម្មវិធីគាំទ្រថ្នាក់ជាតិ កម្មវិធីកិច្ចសហប្រតិបត្តិការអន្តរជាតិ និងព័ត៌មានទាក់ទងនឹងបណ្តាញទំនាក់ទំនងក្នុងស្រុក តំបន់ ជាតិ អន្តរជាតិ ដែលមានស្រាប់
- ការធ្វើអោយប្រសើរឡើងនូវសេវាគាំទ្រដល់ការលក់។

A3.32៖ សម្របសម្រួលសមភាពយេនឌ័រ តាមរយៈ៖

a) យុទ្ធនាការលើកកម្ពស់ការយល់ដឹងសម្រាប់ការសម្របសម្រួលសមភាពយេនឌ័រក្នុងការចែកចាយតួនាទី និងសកម្មភាពនៅក្នុងខ្សែសង្វាក់តម្លៃ។
b) ការពង្រឹងសមត្ថភាពរបស់ស្ត្រីក្នុងការប្រយុទ្ធប្រឆាំងនឹងការយាយី/បៀតបៀន (ការកំណត់(សម្គាល់)បញ្ហា/ហេតុការណ៍, ធ្វើការរាយការណ៍ ឬបរិហារវា, ផ្ទៀងផ្ទាត់ប្រសិនបើវាកើតឡើងចំពោះស្ត្រីផ្សេងទៀត, ដឹងពីច្បាប់ និងសិទ្ធិរបស់ស្ត្រី)។
c) គាំទ្រ TVET ក្នុងការធ្វើឲ្យប្រសើរឡើងនូវការផ្តល់ជូនសេវារបស់ពួកគេក្នុងការដាក់បញ្ចូលវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ស្ត្រី រួមទាំងបញ្ហាដូចជា៖ ការលើកកម្ពស់ការយល់ដឹង, ការគោរពខ្លួនឯង, គោល

ការណ៍សមភាពយេនឌ័រ, អំណាចក្នុងការចចរចា, ការការពារប្រឆាំងនឹងការបៀតបៀន; ព័ត៌មានអំពីឱកាសការងារ; ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ការឆ្លើយតបទៅនឹងឱកាសការងារ; ភាពជាសហគ្រិន

d) ការផ្តល់ព័ត៌មានអំពីសេវាកម្មសហគ្រាសធុនតូច និងមធ្យម (SMME) ដែលគ្រប់គ្រងដោយស្ត្រី និងយុវជន

e) ការធ្វើឲ្យប្រសើរឡើងនូវសេវាកម្មអាជីវកម្មសម្រាប់ស្ត្រី

## ជំពូកទី ៦. សេចក្តីសន្និដ្ឋាន

**ការសន្និដ្ឋានសំខាន់ពីរអាចត្រូវបានព្រាងដូចខាងក្រោម៖**

1) ការពង្រឹងយន្តការអភិបាលកិច្ចសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានក្នុងខេត្តរតនគិរី

2) ការសំយោគគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសំខាន់ៗ

**<u>ការពង្រឹងយន្តការអភិបាលកិច្ចសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងខេត្តរតនគិរី</u>**

យន្តការអភិបាលកិច្ចសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានក្នុងខេត្តរតនគិរី ត្រូវបានពង្រឹងជាបីផ្នែក (សូមមើលរូបខាងក្រោម)៖

a) ស្ថាប័នគ្រប់គ្រងសំខាន់ ដែលជាវេទិកាសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព (វេទិកា**ផ្លាសិដ** PLASED)

b) ក្រុមរងដែលមានមុខងារនិងរចនាសម្ព័នច្បាស់លាស់ ដែលជាគណៈកម្មាធិការខ្សែសង្វាក់តម្លៃ (VAC)

c) ស្ថាប័នប្រតិបត្តិ ដែលជា ប្រព័ន្ធសេវាកម្មទូលំទូលាយ **កុស្ស**(COSS)

ភារកិច្ចចម្បងរបស់វេទិកា **ផ្លាសិដ**(PLASED) គឺ៖

- ព្រាងយុទ្ធសាស្ត្រទីផ្សារក្នុងតំបន់
- ការសហការណ៍ជាមួយរដ្ឋាភិបាលសម្រាប់ការធ្វើឲ្យប្រសើរឡើងនូវការអនុវត្តផែនការរបស់រដ្ឋាភិបាលទាក់ទងនឹងការអភិវឌ្ឍន៍ខេត្តរតនគិរី
- ការសម្របសម្រួលលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ តាមរយៈការផ្តល់ហិរញ្ញប្បទានគម្រោង ការចូលរួមដេញថ្លៃ ការប្រើប្រាស់ទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន ការផ្តល់មូលនិធិ ។ល។
- គាំទ្រការកសាងសម្ព័ន្ធភាពជាមួយតួអង្គជាតិ និងអន្តរជាតិដែលពាក់ព័ន្ធដទៃទៀត។

ភារកិច្ចចម្បងរបស់ គណៈកម្មាធិការខ្សែសង្វាក់តម្លៃ (VAC) គឺ៖

- ផ្តល់គំនិតផ្តួចផ្តើមនានា ដែលមានប្រយោជន៍ចំពោះការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃប្រកបដោយការប្រកួតប្រជែង បរិយាប័ន្ន និរន្តរភាព និងភាពធន់
- ការសម្រួលដល់ការធ្វើពាណិជ្ជកម្ម (អាចតាមរយៈការជួលសហករណ៍ឯកទេស - ការជួលអ្នកឯកទេសឲ្យធ្វើការឲ្យ) តាមរយៈគោលនយោបាយម៉ាកយីហោ និងការផ្សាយពាណិជ្ជកម្ម ការលើកកម្ពស់ការទិញរួម និងការប្រើប្រាស់គ្រឿងចក្រដែលមានតម្លៃថ្លៃ ដើម្បីកាត់បន្ថយការចំណាយ (លាងសម្អាត ស្ងោរ ។ល។) សមត្ថភាពចរចាជាមួយអ្នកលក់ដុំ ហាង តាមផ្សារ ផ្សារទំនើប ខ្សែសង្វាក់ពាណិជ្ជកម្ម។ល។
- ការសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងថ្នាក់ជាតិ ដើម្បីសម្រេចបាននូវប្រព័ន្ធព័ត៌មានដែលអាចចូលប្រើប្រាស់បាន ឬទទួលបាននូវព័ត៌មានទាក់ទងនឹងវិធានការជាតិ ជាពិសេសទៅលើខ្សែសង្វាក់តម្លៃ និងការ

DRAFT

ណែនាំពីការលើកទឹកចិត្តថ្នាក់ជាតិ ឬវិធានការណ៍ដើម្បីគាំទ្រខ្សែសង្វាក់តម្លៃ ជាពិសេសទៅលើការចាប់ផ្តើមអាជីវកម្ម និងយន្តការហិរញ្ញវត្ថុជាក់លាក់។

- ការភ្ជាប់តួអង្គនៃខ្សែសង្វាក់តម្លៃស្វាយចន្ទីជាមួយបណ្តាញអន្តរជាតិដែលស្រដៀងគ្នាផ្សេងទៀតទាក់ទងនឹងបច្ចេកវិទ្យាថ្មីៗ

**<u>ភារកិច្ចចម្បងរបស់ គុស្ស(COSS) គឺ៖</u>**

- ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មអាជីវកម្ម និងលទ្ធភាពទទួលបាន ឬប្រប្រាស់សេវាទាំងនោះ ដោយផ្តល់អាទិភាពដល់សេវាកម្មដូចខាងក្រោម៖
  - សេវាបច្ចេកទេស រដ្ឋបាល អង្គការ/ស្ថាប័ន
  - ទីផ្សារ/ពាណិជ្ជកម្ម
  - គាំទ្រក្នុងការអភិវឌ្ឍន៍សហករណ៍ កិច្ចសហប្រតិបត្តិការ/បណ្តាញទំនាក់ទំនង
  - គាំទ្រក្នុងការអភិវឌ្ឍន៍សម្ព័ន្ធភាព/សមាគម
  - គាំទ្រទាក់ទងនឹងបច្ចេកវិទ្យាថ្មីៗ
  - សេវាកម្មសម្រាប់និរន្តរភាពបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់បម្រែបម្រួលអាកាសធាតុ ដោយផ្តល់អាទិភាពដល់សេវាកម្មដែលទាក់ទងនឹងសេដ្ឋកិច្ចជារង្វង់។
  - សម្រួលសម្រួលលទ្ធភាពក្នុងការទទួលបានប្រាក់កម្ចី/ឥណទាន

**រូបភាពទី 7. វេទិកាអភិបាលកិច្ចក្នុងខេត្តរតនគិរីសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច** (ប្រភព ILS LEDA)




**<u>ការសំយោគគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសំខាន់ៗ</u>**

ប្រអប់ខាងក្រោមបង្ហាញពីការសំយោគនៃគោលការណ៍ណែនាំជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ខ្សែសង្វាក់**តម្លៃ**ស្វាយចន្ទីសម្រាប់អាទិភាពលេខ ១៖

**ប្រអប់ទី 2. ការសំយោគគោលការណ៍ណែនាំអំពីការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃស្វាយចន្ទីសម្រាប់អាទិភាពលេខ ១**
(ប្រភព ILS LEDA)

| | កម្រិតខ្សែសង្វាក់តម្លៃច្រើន | កម្រិតខ្សែសង្វាក់តម្លៃ |
|---|---|---|
| **អភិបាលកិច្ច** | បង្កើតវេទិកា**ផ្លាសិដ**(PLASED) (វេទិកាសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព) ដែលជាយន្តការសម្រាប់ពង្រឹងកិច្ចសន្ទនាសង្គម និងរក្សាបាននូវអត្ថប្រយោជន៍ប្រកួតប្រជែង និងបង្កើតការងារ។ | បង្កើតគណកម្មាធិការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃស្វាយចន្ទីដោយផ្អែកលើអ្នកចូលរួមក្រុមស្នូល និងជាក្រុមរងនៃវេទិកា **ផ្លាសិដ**(PLASED) |
| | | ពង្រឹងនិរន្តរភាពបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ |
| **ការកសាងសមត្ថភាព** | | កសាងសមត្ថភាពបច្ចេកទេស និងសហគ្រិន ដើម្បីជំរុញការអនុវត្តការស្តារឡើងវិញនូវគុណភាពដី និងរក្សាការគ្រប់គ្រងបរិស្ថានដែលមានសុខភាពល្អ ដើម្បីទាញប្រយោជន៍ពីបរិស្ថានមកប្រើប្រាស់ ដូចជាជីសរីរាង្គមួយចំនួន និងប្រយោជន៍ផ្សេងទៀត។ |
| | | ពង្រឹងសមត្ថភាពរបស់សហគ្រិន (ការធ្វើទីផ្សារ ចំណេះដឹងបែបប្រពៃណី) |
| | | ធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់អ្នកផ្តល់សេវាកម្ម (ការចាប់ផ្តើមអាជីវកម្ម ហិរញ្ញប្បទានគម្រោងបច្ចេកទេស រដ្ឋបាល សេវារៀបចំ សេវាទីផ្សារ ការផ្ទេរ ឬផ្តល់ជូនបច្ចេកវិទ្យាថ្មី) |
| **សេវាកម្ម** | បង្កើត **កុស្ស**COSS (ប្រព័ន្ធសេវាកម្មទូលំទូលាយ) សម្រាប់ការផ្តល់សេវាសេដ្ឋកិច្ចសង្គមប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល | ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មអាជីវកម្ម (ទីផ្សារ បច្ចេកទេស រដ្ឋបាល សេវាកម្មអង្គការ ការចាប់ផ្តើមអាជីវកម្ម) |
| | | ផ្តល់ការគាំទ្រដើម្បីបង្កើតសហករណ៍ បណ្តាញទំនាក់ទំនង សម្ព័ន្ធភាព/សមាគម |
| | | ផ្តល់ព័ត៌មាន និងការគាំទ្រទាក់ទងនឹងសេវាកម្មហិរញ្ញវត្ថុ |
| | | ផ្តល់ព័ត៌មាន និងសេវាកម្មគាំទ្រទាក់ទងនឹងបច្ចេកវិទ្យាថ្មីៗ |

DRAFT

ប្រអប់ខាងក្រោមបង្ហាញពីការសំយោគនៃគោលការណ៍ណែនាំជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃស្វាយចន្ទីសម្រាប់អាទិភាពលេខ ២៖

**ប្រអប់ទី ៣. ការសំយោគគោលការណ៍ណែនាំអំពីការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃស្វាយចន្ទីសម្រាប់អាទិភាពលេខ ២**
(ប្រភព ILS LEDA)

| | ខ្សែសង្វាក់តម្លៃច្រើនកម្រិត | ខ្សែសង្វាក់តម្លៃច្រើនកម្រិត |
|---|---|---|
| **អភិបាលកិច្ច** | | ផ្តល់អាទិភាពដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ |
| | | គាំទ្របរិយាប័ន្នសង្គម តាមរយៈការសហការណ៍ជាមួយរដ្ឋាភិបាលជាតិ (ទាក់ទងនឹងសមភាពយេនឌ័រ លទ្ធភាពទទួលបានកម្លាំងពលកម្ម(ការងារ)សម្រាប់មនុស្សដែលមានសមត្ថភាពរាងកាយ និងផ្លូវចិត្តខុសៗគ្នា, ជីវភាពរស់នៅរបស់ក្រុមជាក់លាក់នៅក្នុងសហគមន៍, ការបង្កើតការងារជាផ្លូវការ) |
| | | ការធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ |
| | | សហការណ៍ជាមួយរដ្ឋាភិបាល ដើម្បីបង្កើនប្រសិទ្ធភាពនៃគោលនយោបាយ និងបទប្បញ្ញត្តិសាធារណៈស្តីពីនិរន្តរភាពបរិស្ថាន និងសេដ្ឋកិច្ចបៃតង និងយន្តការឆ្លើយតបសម្រាប់ការប្រឈមមុខនឹងភាពអាសន្ន។ |
| | | ការរៀបចំអង្គការដែលផ្តល់ជំនួយទៅវិញទៅមក; វត្តមានរបស់ក្រុមសង្គ្រោះស្ម័គ្រចិត្តដែលត្រូវបានបណ្តុះបណ្តាល |
| | | ការសម្របសម្រួលពាណិជ្ជកម្ម (យុទ្ធសាស្ត្រទីផ្សារ, ការលក់តាមអ៊ីនធឺណិត និងតាមទូរស័ព្ទ, ការរៀបចំព្រឹត្តិការណ៍/វេទិកា, អង្គភាពសាធារណៈ, ការធ្វើពាណិជ្ជកម្មដោយយុត្តិធម៌) |
| | | កិច្ចព្រមព្រៀងជាមួយវិទ្យាស្ថានឯកទេសសម្រាប់ការធ្វើឲ្យប្រសើរឡើងនូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ |
| | | គាំទ្រដល់និរន្តរភាពបរិស្ថាន សេដ្ឋកិច្ចបៃតង និងសេដ្ឋកិច្ចជារង្វង់។ |
| | | ជំរុញការច្នៃប្រឌិតថ្មីនៅក្នុងខ្សែសង្វាក់តម្លៃស្វាយចន្ទី ជាពិសេសចំពោះការសម្របសម្រួល/ធ្វើឲ្យប្រសើរឡើងនូវ |

DRAFT

| | | |
|---|---|---|
| | | ការស្រាវជ្រាវក្នុងវិស័យអភិរក្សគ្រាប់ពូជ និងជំងឺរុក្ខជាតិ។ |
| **ការកសាងសមត្ថភាព** | | ធ្វើឱ្យប្រសើរឡើងនូវជំនាញវិជ្ជាជីវៈដូចជា (រដ្ឋបាល, លទ្ធកម្មផលិតផល, ទីផ្សារ, ការដឹកជញ្ជូន និងការរក្សាទុក/ទុកដាក់(ក្នុងឃ្លាំង), បច្ចេកវិទ្យាចាប់សញ្ញាពីចម្ងាយ និងឌីជីថល, បច្ចេកវិទ្យាមនុស្សយន្ត និងស្វ័យប្រវត្តិកម្ម, បញ្ញាសិប្បនិម្មិត (AI) ។ |
| | | ការបណ្ដុះបណ្ដាលបុគ្គលិកដែលមានជំនាញទាប |
| | | ធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគ្រិន (ពូជភាពជាអ្នកដឹកនាំ សេដ្ឋកិច្ចវង្វង់។ |
| **សេវាកម្ម** | ការសម្របសម្រួលការផ្គូផ្គងរវាងតម្រូវការការងារ និងការផ្គត់ផ្គង់ | ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មសម្រាប់និរន្តរភាពសង្គម (ទំនួលខុសត្រូវសង្គមសម្រាប់ការវិនិយោគសង្គម សហគ្រិនវ័យក្មេង ការងារសម្រាប់ជនមានពិការភាព (ផ្លូវចិត្ត និង/ឬរាងកាយ) និងមនុស្សដែលមានជំនាញវិជ្ជាជីវទាប |
| | | ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មសម្រាប់និរន្តរភាពបរិស្ថាន |